**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍**
**ទេសចរណ៍សៀមរាប-អង្គរ**
**លេខ: ០០៣.សសរ.គអទស**

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី

## ប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងការបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងសេចក្តីសម្រេចលេខ ០០៥ សសរ.គអទស ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម ប្រាក់ សោភ័ណ | អភិបាល នៃគណៈអភិបាលខេត្តសៀមរាប និងជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប | ប្រធាន |
| ២- ឯកឧត្តម នី ផល្លី | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- លោក ង៉ូវ សេងកាក់ | អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក សេង សុធារ៉ា | ប្រធាននាយកដ្ឋាន នៃអាជ្ញាធរជាតិអប្សរា | អនុប្រធាន |
| ៥- លោក គី វីរិទ្ធ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប | សមាជិក |
| ៦- លោក ហ៊ី សាយ | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តសៀមរាប | សមាជិក |
| ៧- លោក ទូច ម៉ាឡា | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប | សមាជិក |
| ៨- លោក ធិម សេរីវុឌ្ឍ | ប្រធានស្តីទីនៃមន្ទីរទេសចរណ៍ខេត្តសៀមរាប | សមាជិក |
| ៩- លោក រិន ឡូត | អភិបាល នៃគណៈអភិបាលស្រុកបន្ទាយស្រី | សមាជិក |
| ១០- លោក ងន ប៊ុនធី | អភិបាលរង នៃគណៈអភិបាលស្រុកបន្ទាយស្រី | សមាជិក |
| ១១- លោក សាំង វត្តនា | អភិបាលរង នៃគណៈអភិបាលស្រុកបន្ទាយស្រី | សមាជិក |
| ១២- លោក ហួរ ដាណេ | នាយករដ្ឋបាលស្រុកបន្ទាយស្រី | សមាជិក |
| ១៣- លោក ម៉ម ចន្ថា | ប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ សាលាខេត្តសៀមរាប | សមាជិក |
| ១៤- លោក សេង ប៊ុនថា | ប្រធានការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន សាលាខេត្តសៀមរាប | សមាជិក |
| ១៥- លោក ស ខេង | មន្ត្រីការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ចសាលាខេត្តសៀមរាប | សមាជិក |
| ១៦- លោក យូ ចន្ថា | មន្ត្រីបច្ចេកទេស នៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| ១៧- លោក ចាន់ សំណាង | មន្ត្រីបច្ចេកទេស នៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| ១៨- លោក លាន សូវ៉ាឡង់ | មន្ត្រីបច្ចេកទេស នៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| ១៩- លោក សេក វីដា | មន្ត្រីបច្ចេកទេស នៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| ២០- លោកស្រី វាសនា មករា | បុគ្គលិកបច្ចេកទេស នៃអាជ្ញាធរជាតិអប្សរា | សមាជិក |

**ប្រការ២.-**

ប្រធាន អនុប្រធាន និងសមាជិកការិយាល័យចំណុះទាំង០៥ ដូចមានចែងក្នុងសេចក្តីសម្រេចលេខ ០០៥ សសរ.គអទស ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី។

**ប្រការ៣.-**

រាល់កិច្ចប្រជុំនានារបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី ត្រូវអញ្ជើញតំណាងលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរចូលរួម។

**ប្រការ៤.-**

អនុប្រធាន សមាជិក អង្គភាពក្រោមចំណុះគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងគ្រប់អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៩រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥

**ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការគ្រប់គ្រង**
**និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**ហោង ខុន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ខុទ្ទកាល័យ**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរជាតិអប្សរា
- រដ្ឋបាលខេត្តសៀមរាប
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ